**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
**អគ្គនាយកដ្ឋានពន្ធដារ**
លេខ ៨៧១៣ អពដ

L202105060072 | TD3512

ថ្ងៃអង្គារ ៧កើត ខែជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២១

# សេចក្តីជូនដំណឹង
## ស្តីពី
## កាលបរិច្ឆេទបញ្ជូនរបាយការណ៍ព័ត៌មានគណនីជនជាតិអាមេរិកដែលត្រូវរាយការណ៍ (U.S. Reportable Accounts) សម្រាប់ឆ្នាំប្រតិទិន២០២០ របស់ធនាគារ សហគ្រាសធានារ៉ាប់រង និងគ្រឹះស្ថានហិរញ្ញវត្ថុ

អគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានកិត្តិយសសូមជម្រាបជូនដំណឹងដល់ធនាគារ សហគ្រាសធានារ៉ាប់រង និងគ្រឹះស្ថានហិរញ្ញវត្ថុទាំងអស់ ដែលស្ថិតនៅក្រោមកាតព្វកិច្ចរាយការណ៍អនុលោមតាមកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជានិងរដ្ឋាភិបាលសហរដ្ឋអាមេរិក ដើម្បីធ្វើឱ្យប្រសើរឡើងនូវអនុលោមភាពពន្ធអន្តរជាតិ និងអនុវត្តច្បាប់ស្តីពីអនុលោមភាពពន្ធចំពោះគណនីក្រៅប្រទេសរបស់អាមេរិក (FATCA) ឱ្យបានជ្រាបថា យោងតាមប្រកាសលេខ ១៤៥៩ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីការអនុវត្តកិច្ចព្រមព្រៀង FATCA ធនាគារ សហគ្រាសធានារ៉ាប់រង និងគ្រឹះស្ថានហិរញ្ញវត្ថុទាំងអស់ត្រូវបញ្ជូនរបាយការណ៍ព័ត៌មានគណនីជនជាតិអាមេរិកដែលត្រូវរាយការណ៍សម្រាប់ឆ្នាំប្រតិទិន២០២០ ទៅអាជ្ញាធរចំណូលផ្ទៃក្នុងសហរដ្ឋអាមេរិក (U.S. Internal Revenue Service-IRS) តាមរយៈអគ្គនាយកដ្ឋានពន្ធដារ **ឱ្យបានត្រឹមថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២១ ជាកំហិត។** លើសពីនេះ អគ្គនាយកដ្ឋានពន្ធដារក៏សូមជម្រាបជូនថា ធនាគារ សហគ្រាសធានារ៉ាប់រង និងគ្រឹះស្ថានហិរញ្ញវត្ថុទាំងអស់ត្រូវពិនិត្យ និងផ្ទៀងផ្ទាត់របាយការណ៍គណនីជនជាតិអាមេរិកដែលត្រូវរាយការណ៍តាមទម្រង់និងបទដ្ឋានរបស់ IRS ឱ្យបានត្រឹមត្រូវ មុននឹងបញ្ជូនរបាយការណ៍នេះទៅក្នុងប្រព័ន្ធបញ្ជូនរបាយការណ៍ IDES Gateway ដោយអគ្គនាយកដ្ឋានពន្ធដារនឹងសម្របសម្រួលបញ្ជូនរបាយការណ៍នេះបន្តទៅ IRS។

ក្នុងករណីមានកំហុស និងហួសកាលកំណត់ ធនាគារ សហគ្រាសធានារ៉ាប់រង និងគ្រឹះស្ថានហិរញ្ញវត្ថុទាំងអស់ដែលស្ថិតនៅក្រោមកាតព្វកិច្ចរាយការណ៍អនុលោមតាមកិច្ចព្រមព្រៀង FATCA ត្រូវទទួលខុសត្រូវដោយខ្លួនឯងចំពោះការពិន័យនានាអនុលោមតាមកិច្ចព្រមព្រៀងនិងប្រកាសនេះ។

ទន្ទឹមនឹងនេះ អគ្គនាយកដ្ឋានពន្ធដារ ក៏សូមជម្រាបជូនដំណឹងដែរថា ធនាគារ សហគ្រាសធានារ៉ាប់រង និងគ្រឹះស្ថានហិរញ្ញវត្ថុទាំងអស់ អាចចូលទៅកាន់គេហទំព័រ fatca.gov.kh ដើម្បីទាញយក HCTA Public Key និងទទួលបានព័ត៌មានទាក់ទិននឹងតម្រូវការ FATCA របស់ IRS។

ក្នុងករណីមានសំណួរ ឬចម្ងល់ផ្សេងៗ សូមទំនាក់ទំនងមកអាសយដ្ឋានសារអេឡិចត្រូនិក fatca@tax.gov.kh ឬទូរស័ព្ទលេខ ០២៣ ៨៨៣ ៧២៧។

**រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី**
**ប្រតិភូរាជរដ្ឋាភិបាល**
**ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ**

**គង់ វិបុល**